**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

********

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០៥.០៨៩/១២ គ.ជ.ប.អគ្គ.ពស**

រាជធានីភ្នំពេញ ថ្ងៃទី 24 ខែឧសភា ឆ្នាំ២០១២

# គ.ជ.ប ក្រើនរំលឹកដល់ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកធ្វើអត្ថាធិប្បាយត្រូវគោរពច្បាប់បោះឆ្នោត

ដោយសង្កេតឃើញពីសភាពនៃការឃោសនាបោះឆ្នោត ក្នុងរយៈពេលពីថ្ងៃចាប់ផ្តើមរហូតមកដល់ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២នេះ មានគណបក្សនយោបាយ បេក្ខជន និងអ្នកគាំទ្រ អង្គការ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានភាគច្រើនបានអនុវត្តត្រឹមត្រូវតាមច្បាប់ ប៉ុន្តែមជ្ឈដ្ឋាន និងបុគ្គលមួយចំនួនមិនគោរពត្រឹមត្រូវតាមច្បាប់បោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានចេញសេចក្តីណែនាំរំលឹកមួយលេខ ៨៧៥/១២ គ.ជ.ប ស្តីពីការផ្សព្វផ្សាយ និងការធ្វើអត្ថាធិប្បាយព័ត៌មានទាំងអស់ ត្រូវយកចិត្តទុកដាក់ គោរព និងអនុវត្តយ៉ាងម៉ឺងម៉ាត់នូវច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ក្រមសីលធម៌ គោលការណ៍នៃការឃោសនាបោះឆ្នោត និងគោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ។

នៅក្នុងសេចក្តីណែនាំរំលឹកនោះបានលើកឡើងថា ៖

- គណបក្សនយោបាយ បេក្ខជន អ្នកគាំទ្រ អង្គការសង្កេតការណ៍បោះឆ្នោត និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងអស់ ត្រូវយកចិត្តទុកដាក់គោរព និង អនុវត្តយ៉ាងម៉ឺងម៉ាត់នូវច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ក្រមសីលធម៌ គោលការណ៍នៃការឃោសនាបោះឆ្នោត និងគោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ។

- អ្នកយកព័ត៌មាន អ្នករាយការណ៍ និងអ្នកធ្វើអត្ថាធិប្បាយ ត្រូវជៀសវាងសម្តែងចេញនូវនិន្នាការនយោបាយ ការមាក់ងាយ ឬការប្រមាថ តាមរយៈការលើកដាក់សម្លេង ឬឥរិយាបថជាក់ស្តែងផ្សេងទៀត ។

- ក្នុងដំណាក់កាលឃោសនាបោះឆ្នោតនេះ ការផ្សព្វផ្សាយណាមួយដែលមិនអនុវត្តតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត និងសេចក្តីណែនាំរំលឹកនេះ គ.ជ.ប នឹងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន ។

ព័ត៌មានបន្ថែមទំនាក់ទំនង ៖ ០២៣ ២១៨ ៣៧៨ / ០១២ ៨៥៥ ០១៨ ; E-mail: necinfo@forum.org.kh ; www.necelect.org.kh